រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ១៦៤៤ ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការគ្រប់គ្រងអាកាសយានគ្មានមនុស្សបើក (ដ្រូន)

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ　　រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ　　រដ្ឋមន្ត្រីទទួលបន្ទុក រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២៣/០២០ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៥៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១._**

ប្រកាសអន្តរក្រសួងនេះកំណត់អំពីការគ្រប់គ្រងទិន្នន័យ តំបន់ហាមឃាត់ និងការប្រើប្រាស់អាកាសយានគ្មានមនុស្សបើក(ដ្រូន) ព្រមទាំងកំណត់អំពីវិធានការសន្តិសុខក្នុងការប្រើប្រាស់អាកាសយានគ្មានមនុស្សបើក(ដ្រូន) ដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២._**

ប្រកាសអន្តរក្រសួងនេះមានវិសាលភាពអនុវត្តចំពោះអាកាសយានគ្មានមនុស្សបើក(ដ្រូន) ដែលអាចផ្ទុកទម្ងន់ចាប់ពី២(ពីរ)គីឡូក្រាមឡើង លើកលែងតែអាកាសយានគ្មានមនុស្សបើក(ដ្រូន) ដែលប្រើប្រាស់សម្រាប់បម្រើឱ្យវិស័យការពារជាតិ និងសន្តិសុខជាតិ ដែលត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**ប្រការ៣._**

ក្រសួងមហាផ្ទៃ មានសមត្ថកិច្ចគ្រប់គ្រងទិន្នន័យ និងការប្រើប្រាស់អាកាសយានគ្មានមនុស្សបើក(ដ្រូន) ដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះ។

ក្រសួងមហាផ្ទៃ ត្រូវចែករំលែកព័ត៌មានពីទិន្នន័យអាកាសយានគ្មានមនុស្សបើក(ដ្រូន) ជូនដល់ក្រសួងស្ថាប័នពាក់ព័ន្ធ បន្ទាប់ពីទទួលបាននូវទិន្នន័យស្វ័យប្រកាសពីបុគ្គលដែលគ្រប់គ្រង កាន់កាប់ និងប្រើប្រាស់អាកាសយានគ្មានមនុស្សបើក(ដ្រូន)ដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះ។

## ជំពូកទី៣
## ការគ្រប់គ្រងទិន្នន័យ និងការប្រើប្រាស់

**ប្រការ៤._**

បុគ្គលដែលកំពុងគ្រប់គ្រង កាន់កាប់ ឬប្រើប្រាស់អាកាសយានគ្មានមនុស្សបើក(ដ្រូន) ដូចមានចែងក្នុងប្រការ២នៃប្រកាសនេះ ត្រូវធ្វើស្វ័យប្រកាសទិន្នន័យអាកាសយានគ្មានមនុស្សបើក(ដ្រូន) នៅអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ នៃទីកន្លែងដែលអាកាសយានគ្មានមនុស្សបើក(ដ្រូន) ស្ថិតនៅ។

អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ដែលទទួលទិន្នន័យស្វ័យប្រកាស ត្រូវបញ្ជូនព័ត៌មានទិន្នន័យទាំងនោះទៅក្រសួងមហាផ្ទៃ តាមឋានានុក្រម និងចែករំលែកព័ត៌មានទៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំពោះអាកាសយានគ្មានមនុស្សបើក(ដ្រូន)ដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះ ដែលប្រើប្រាស់ក្នុងវិស័យកសិកម្ម។

ការធ្វើស្វ័យប្រកាសទិន្នន័យអាកាសយានគ្មានមនុស្សបើក(ដ្រូន) ដែលកំណត់ក្នុងប្រកាសនេះ មិនតម្រូវឱ្យបង់កម្រៃសេវាឡើយ។

ទម្រង់បែបបទនៃការធ្វើស្វ័យប្រកាសអាកាសយានគ្មានមនុស្សបើក(ដ្រូន) ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៥._**

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវគ្រប់គ្រងទិន្នន័យ និងការប្រើប្រាស់អាកាសយានគ្មានមនុស្សបើក(ដ្រូន)ដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះ ក្នុងវិស័យកសិកម្ម នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ជំពូកទី៤

## លក្ខខណ្ឌ និងបម្រាមនៃការបង្ហោះអាកាសយានគ្មានមនុស្សបើក(ដ្រូន)

**ប្រការ៦._**

អ្នកបង្ហោះអាកាសយានគ្មានមនុស្សបើក(ដ្រូន) ដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះ ត្រូវគោរពលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ
- ត្រូវបង្ហោះចាប់ពីម៉ោង៦ព្រឹក ដល់ម៉ោង៦ល្ងាច។ ក្នុងករណីខុសពីម៉ោងនេះ ត្រូវមានការអនុញ្ញាតដោយឡែក
- ត្រូវយល់ដឹងពីការព្យាករអាកាសធាតុនៅតំបន់ដែលត្រូវបង្ហោះ
- មិនត្រូវបង្ហោះសំកាំង ឬឆ្វែលពីលើទីតាំងឯកជន លើកលែងតែមានការអនុញ្ញាតពីម្ចាស់ទីតាំងនោះ
- មិនត្រូវថតរូប ថតសំឡេង ឬថតវីដេអូ ដោយគ្មានការអនុញ្ញាតឡើយ លើកលែងតែការថតនោះមិនសំដៅដល់ការកំណត់អត្តសញ្ញាណជនណាម្នាក់ ឬក្រុមជាក់លាក់ណាមួយ
- មិនត្រូវបង្ហោះពីលើក្រុមមនុស្ស លើកលែងតែមានការអនុញ្ញាតដោយឡែក
- មិនត្រូវបង្ហោះពីលើហ្វូងសត្វ លើកលែងតែមានការអនុញ្ញាតដោយឡែក
- មិនត្រូវបង្ហោះពីលើរាល់ទីតាំងដែលមានឧបទ្ទវហេតុ អគ្គិភ័យ រលំអគារ ធ្លាក់យន្តហោះ គ្រោះថ្នាក់ចរាចរណ៍ ឬឧបទ្ទវហេតុផ្សេងៗទៀត ដែលកំពុងស្ថិតក្នុងប្រតិបត្តិការសង្គ្រោះរបស់សមត្ថកិច្ច លើកលែងតែមានការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងប្រតិបត្តិការនោះ
- មិនត្រូវបង្ហោះពីលើ ឬនៅក្បែរតំបន់កំពុងប្រតិបត្តិការរបស់សមត្ថកិច្ច
- មិនត្រូវបង្ហោះបដាផ្សព្វផ្សាយ ឬបាចខិតបណ្ណឃោសនាផ្សេងៗ លើកលែងតែមានការអនុញ្ញាតដោយឡែក
- មិនត្រូវបង្ហោះអាកាសយានគ្មានមនុស្សបើក(ដ្រូន) ជាក្រុម ចាប់ពី៥គ្រឿងឡើងទៅ លើកលែងតែមានការអនុញ្ញាតដោយឡែក
- ត្រូវទទួលខុសត្រូវព្យសនកម្មចំពោះសកម្មភាពរបស់ខ្លួន
- មិនត្រូវបង្ហោះក្នុងរង្វង់៥០០(ប្រាំរយ)ម៉ែត្រ ពីអាកាសយានដែលកំពុងហោះហើរគ្រប់ប្រភេទ
- មិនត្រូវបង្ហោះក្នុងតំបន់ហាមឃាត់
- មិនត្រូវបង្ហោះក្នុងរង្វង់១០០(មួយរយ)ម៉ែត្រពីនាវា កប៉ាល់ ឬកាណូតឯកជន លើកលែងតែមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច
- មិនត្រូវដឹកជញ្ជូនសារធាតុមានគ្រោះថ្នាក់គ្រប់ប្រភេទ
- មិនត្រូវបង្ហោះស្ថិតក្រោមស្ថានភាពស្រវឹង ឬក្រោមឥទ្ធិពលនៃគ្រឿងញៀន។

ក្នុងករណីអ្នកបង្ហោះមិនគោរពលក្ខខណ្ឌខាងលើនេះ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការតាមផ្លូវច្បាប់មានជាធរមាន។

**ប្រការ៧._**

លើកលែងតែមានការអនុញ្ញាតពីស្ថាប័នសាមី ឬម្ចាស់ទីតាំង អាកាសយានគ្មានមនុស្សបើក(ដ្រូន) មិនត្រូវបង្ហោះនៅក្នុងតំបន់ហាមឃាត់ដូចខាងក្រោម៖

- ព្រះបរមរាជវាំង
- ស្ថាប័នរដ្ឋ
- មន្ទីរពេទ្យ សាលារៀន និងផ្សារ
- ពហុកីឡាដ្ឋាន
- តំបន់រមណីយដ្ឋានអង្គរ និងបរិវេណប្រាសាទ
- លំនៅដ្ឋានប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី
- និវេសនដ្ឋានទូត ស្ថានទូត អគ្គកុងស៊ុល និងអង្គការអន្តរជាតិ
- មូលដ្ឋានយោធា និងមូលដ្ឋាននគរបាលជាតិ
- ទីតាំង ឬឃ្លាំងស្តុកសារធាតុងាយឆេះ ឬងាយផ្ទុះឆេះ
- ស្ថានីយវិទ្យុ ស្ថានីយទូរទស្សន៍ រោងចក្រចម្រាញ់ប្រេង ឧស្ម័ន រ៉ែ រោងចក្រអគ្គិសនី និងអនុស្ថានីយអគ្គិសនី។

តំបន់ហាមឃាត់ផ្សេងទៀតនៃការបង្ហោះអាកាសយានគ្មានមនុស្សបើក(ដ្រូន) ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**ប្រការ៨._**

អ្នកបង្ហោះអាកាសយានគ្មានមនុស្សបើក(ដ្រូន) ដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះ ត្រូវជូនដំណឹងទៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ នៃទីកន្លែងបង្ហោះអាកាសយានគ្មានមនុស្សបើក(ដ្រូន)នោះ មុនធ្វើការបង្ហោះ។

ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ត្រូវរាយការណ៍ពីការបង្ហោះអាកាសយានគ្មានមនុស្សបើក(ដ្រូន) ដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះ ជូនទៅក្រសួងមហាផ្ទៃ តាមឋានានុក្រម ដើម្បីចែករំលែកព័ត៌មានទៅរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ដែលទទួលបានការជូនដំណឹងខាងលើ ត្រូវចែករំលែកព័ត៌មានទៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំពោះការបង្ហោះអាកាសយានគ្មានមនុស្សបើក(ដ្រូន)ដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះ ដែលប្រើប្រាស់ក្នុងវិស័យកសិកម្ម។

**ប្រការ៩._**

អាកាសយានគ្មានមនុស្សបើក(ដ្រូន)ដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះ ត្រូវផ្ទុកទម្ងន់ទៅតាមកម្រិតដែលបានកំណត់ក្នុងបញ្ជីកាបច្ចេកទេសនៃប្រភេទអាកាសយានគ្មានមនុស្សបើក(ដ្រូន)នីមួយៗ។

អាកាសយានគ្មានមនុស្សបើក(ដ្រូន)ដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះមិនត្រូវបង្ហោះលើសកម្ពស់១២០(មួយរយម្ភៃ)ម៉ែត្រ គិតចាប់ពីផ្ទៃដី ឬផ្ទៃទឹក លើកលែងតែមានការអនុញ្ញាតពីរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**ប្រការ១០._**

អាកាសយានគ្មានមនុស្សបើក(ដ្រូន) មិនអនុញ្ញាតឱ្យបង្ហោះក្នុងបរិវេណរង្វង់៣(បី)គីឡូម៉ែត្រ និងកម្ពស់មិនឱ្យលើស៩០(កៅសិប)ម៉ែត្រ ពីរបងនៃអាកាសយានដ្ឋានស៊ីវិល និងអាកាសយានដ្ឋានយោធា។

## ជំពូកទី៥
## ទណ្ឌកម្ម

**ប្រការ១១._**

បុគ្គលដែលគ្រប់គ្រង កាន់កាប់ និងប្រើប្រាស់អាកាសយានគ្មានមនុស្សបើក(ដ្រូន) ពុំគោរពតាមបទប្បញ្ញត្តិដែលមានចែងក្នុងប្រកាសអន្តរក្រសួងនេះ ត្រូវទទួលទណ្ឌកម្មតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ១២._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៣._**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ព្រមទាំងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៦រោច ខែ មាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ឌិត ទីណា**

**រដ្ឋមន្ត្រីទទួលបន្ទុក**
**រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល**

**ម៉ៅ ហាវណ្ណាល់**

**កន្លែងទទួល ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ**

នៃប្រកាសអន្តរក្រសួងលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០២៥ ស្ដីពីការគ្រប់គ្រងអាកាសយានគ្មានមនុស្សបើក (ដ្រូន)។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ទម្រង់បែបបទនៃការធ្វើស្វ័យប្រកាសអាកាសយានគ្មានមនុស្សបើក (ដ្រូន)

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................ភេទ.........អាយុ...........អត្តសញ្ញាណបណ្ណលេខ:......................ទូរស័ព្ទលេខ: ............................អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ:.................ផ្លូវលេខ:............ភូមិ.....................ឃុំ/សង្កាត់.........................ស្រុក/ខណ្ឌ..........................រាជធានី/ខេត្ត.........................។ លេខទូរស័ព្ទទំនាក់ទំនង...................................តេឡេក្រាម ...................................។ ខ្ញុំបាទ/នាងខ្ញុំមានដ្រូនចំនួន...............គ្រឿង និងសូមធ្វើស្វ័យប្រកាសអំពីអាកាសយានគ្មានមនុស្សបើក(ដ្រូន) ដែលកំពុងមាន និងកាន់កាប់ ដូចខាងក្រោម៖

### ក. ព័ត៌មានអំពីអាកាសយានគ្មានមនុស្សបើក (ដ្រូន)

| ល.រ | ក្រុមហ៊ុនផលិត | ម៉ូដែលឬប្រភេទ | លេខសេរី (Serial number) | ប្រទេសផលិត | ទម្ងន់ (ដ្រូន) (គ.ក្រ) | ល្បឿនហោះហើរអតិបរមា (គ.ម) | កម្ពស់ហោះហើរអតិបរមា (ម) | ចម្ងាយហោះហើរ (គ.ម) | រយៈពេលការហោះហើរ (នាទី) | ទម្ងន់ផ្ទុក (គ.ក្រ) |
|---|---|---|---|---|---|---|---|---|---|---|
| ១ | | | | | | | | | | |
| ២ | | | | | | | | | | |
| ៣ | | | | | | | | | | |
| ៤ | | | | | | | | | | |
| ៥ | | | | | | | | | | |
| ៦ | | | | | | | | | | |
| ៧ | | | | | | | | | | |
| ៨ | | | | | | | | | | |
| ៩ | | | | | | | | | | |
| ១០ | | | | | | | | | | |

### ខ. គោលបំណងក្នុងការប្រើប្រាស់អាកាសយានគ្មានមនុស្សបើក (ដ្រូន)

.......................................................................................................................................................

ខ្ញុំបាទសូមធានាទទួលខុសត្រូវចំពោះមុខច្បាប់ថា រាល់ព័ត៌មានដែលបានផ្ដល់ជូនខាងលើ ពិតជាត្រឹមត្រូវប្រាកដមែន ហើយរាល់ពេលមានការផ្លាស់ប្ដូរព័ត៌មានអំពីដ្រូនខាងលើ ខ្ញុំបាទ/នាងខ្ញុំនឹងធ្វើស្វ័យប្រកាសឡើងវិញ។

ថ្ងៃទី...............ខែ...............ឆ្នាំ២០២....

ហត្ថលេខាឬស្នាមមេដៃ